**Declassified to Public**
**28 June 2019**

លេខ៖ D349

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
Office of the Co-Investigating Judges
Bureau des co-juges d'instruction

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 17 / 03 / 2017
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-ស.ច.ស.ក -ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៧

ភាសា ៖ ខ្មែរ/អង់គ្លេស [អង់គ្លេស ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

## សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរលើអង្គហេតុពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មចំនួន ៦ កន្លែង

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី យឹម ទិត្យ**
សូ មូស្សេទ្ធី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីនី
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARTI

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧ នៅក្នុងសេចក្តីជូនដំណឹងអំពីចេតនាបន្ថែមទម្រង់នៃការទទួលខុសត្រូវ តាមវិធីដីកាបង្គាប់របស់តុលាការ និងការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន ("សេចក្តីជូនដំណឹងចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧")[1] ខ្ញុំបានជូនដំណឹងភាគីទាំងអស់អំពីចេតនារបស់ខ្ញុំមិនបន្តស៊ើបសួរលើអង្គហេតុបន្ថែមទៀតពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មដូចខាងក្រោមនៅក្នុងសំណុំរឿង ០០៤៖

- ទីតាំងឧក្រិដ្ឋកម្មទី ៨[2]- អន្លង់វិលប្រែង និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធ
- ទីតាំងឧក្រិដ្ឋកម្មទី ១៤-ការដ្ឋានភ្នំត្រដាក់ចិត្ត
- ទីតាំងឧក្រិដ្ឋកម្មទី ១៥- ទីតាំងសម្លាប់មនុស្ស បន្ទាយអូរតាក្រី
- ទីតាំងឧក្រិដ្ឋកម្មទី ២៣- មន្ទីរសន្តិសុខវត្តកណ្តាល
- ទីតាំងឧក្រិដ្ឋកម្មទី ២៤- មន្ទីរសន្តិសុខវត្តបន្ទាយនាង
- ទីតាំងឧក្រិដ្ឋកម្មទី ២៥-មន្ទីរសន្តិសុខវត្តធម្មយុត

២. នៅក្នុងសេចក្តីជូនដំណឹងចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧ ខ្ញុំបានអញ្ជើញភាគីទាំងអស់ឲ្យដាក់សារណាស្តីពីចេតនាផ្អាកកិច្ចស៊ើបសួរលើអង្គហេតុទាំងនេះ[3]។

៣. នៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់ចម្លើយតបទៅនឹងសេចក្តីជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីចេតនាដាក់បន្ថែមទម្រង់នៃការទទួលខុសត្រូវ តាមវិធីដីកាបង្គាប់របស់តុលាការ និងអំពីការផ្អាកជាបណ្តោះ

---

[1]សំណុំរឿង ០០៤ ឯកសារ D342 *សេចក្តីជូនដំណឹងអំពីចេតនាបន្ថែមទម្រង់នៃការទទួលខុសត្រូវ តាមវិធីដីកាបង្គាប់របស់តុលាការ និងការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន* ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧("សេចក្តីជូនដំណឹងចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧")។

[2]លេខរៀងទីតាំងឧក្រិដ្ឋកម្មដែលប្រើនៅក្នុងឯកសារនេះគឺយោងលើលេខរៀងដែលប្រើនៅក្នុងសំណុំរឿង ០០៤ ឯកសារ D281 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥។

[3]សេចក្តីជូនដំណឹងចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៧ កថាខណ្ឌ ៤៥,៤៨។

អាសន្ន("ចម្លើយតប")[4] ដោយបញ្ជាក់ថា គាត់មិនជំទាស់នឹងការអនុវត្តវិធានផ្ទៃក្នុង ៦៦ *ស្ទួន* ចំពោះទីតាំងឧក្រិដ្ឋកម្មទាំង ៦ នេះទេ[5]។

៤. បន្ថែមពីលើនេះទៀត ស.ព.អ អះអាងថា វិធានផ្ទៃក្នុង ៦៦ *ស្ទួន* គួរតែយកមកប្រើប្រាស់ផងដែរដើម្បីផ្អាកកិច្ចស៊ើបសួរលើការស្វែងរកភស្តុតាងបញ្ជាក់ថាមានជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម("វៀតណាម") ទាក់ទងនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩[6]។

## II. **ពិភាក្សា**

៥. ដោយពិចារណាលើចម្លើយតប និងតាមសំអាងហេតុដូចមាននៅក្នុងសេចក្ដីជូនដំណឹងចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧[7] ទើបខ្ញុំបង្ហាញចេតនាបច្ចុប្បន្នេះចង់ផ្អាកកិច្ចស៊ើបសួរលើអង្គហេតុពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មទាំង ៦ ដូចបានលើកយោងនៅក្នុងកថាខណ្ឌ ១ ខាងលើ។

៦. ដូចបានបញ្ជាក់ពីមុនហើយ[8] វិធីផ្អាកកិច្ចស៊ើបសួរនេះ ដែលមិនមានចែងច្បាស់លាស់នៅក្នុងវិធានផ្ទៃក្នុងទេ គឺធ្វើឡើងដើម្បីផ្ដល់ភាពច្បាស់លាស់ជាអតិបរមា និងការធានាដល់ភាគីទាំងអស់ទាក់ទងនឹងបញ្ហានានាដែលខ្ញុំ និងភាគីទាំងអស់ នឹងត្រូវបែងចែកធនធានមានកំណត់របស់យើង និងដើម្បីធ្វើឱ្យមានប្រសិទ្ធភាពដល់កិច្ចស៊ើបសួរមុនពេលកំណត់ជាផ្លូវដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ៦៦*ស្ទួន* និងមុនពេលបិទកិច្ចស៊ើបសួរ។

៧. ខ្ញុំកត់សម្គាល់លើទឡ្ហីករណ៍របស់ ស.ព.អ ទាក់ទងនឹងការអនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន* ចំពោះអង្គហេតុពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងវៀតណាម

---

[4]សំណុំរឿង ០០៤ ឯកសារ D342/1 *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្ដីជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីចេតនាដាក់បន្ថែមទម្រង់នៃការទទួលខុសត្រូវ តាមវិធីដឹកបង្គាប់របស់តុលាការ និងអំពីការផ្អាកជាបណ្ដោះអាសន្ន* ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៧ ("ចម្លើយតប")។

[5]ចម្លើយតប កថាខណ្ឌ ៣។

[6]ចម្លើយតប កថាខណ្ឌ ៤។

[7]សេចក្ដីជូនដំណឹងចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៧ កថាខណ្ឌ ៩-៤៤។

[8]សំណុំរឿង ០០៤ ឯកសារ D302/3 *សេចក្ដីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ* ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦។

ប៉ុន្តែ ខ្ញុំមិនជឿថា ចាំបាច់ត្រូវអនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន* ទេ ហើយខ្ញុំកត់សម្គាល់ថា កិច្ចស៊ើបសួរលើអង្គហេតុពាក់ព័ន្ធទាំងនេះគឺដល់ចំណុចជ្រៅណាស់ហើយ។ ជាងនេះទៀត អង្គហេតុពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធនេះក៏ពាក់ព័ន្ធនឹងបទចោទអំពីការនិរទេស ដែលជាបទឧក្រិដ្ឋមួយក្នុងចំណោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយត្រូវបានស៊ើបអង្កេតរួចហើយនៅក្នុងបរិបទនេះ។ ហេតុនេះ មិនសមស្របត្រូវអនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន* ដើម្បីបង្កើនល្បឿនកិច្ចដំណើរការនីតិវិធីនោះទេ។

៨. ប្រសិនបើមានការប្រែប្រួលកាលៈទេសៈដែលធ្វើឱ្យខ្ញុំមានយោបល់ផ្សេងពីនេះ ខ្ញុំនឹងជូនដំណឹងភាគីទាំងអស់ក្នុងពេលវេលាសមស្រប។

**តាមសំអាងហេតុខាងលើ ខ្ញុំ៖**

៩. **ជូនដំណឹង** ភាគីទាំងអស់ថា ខ្ញុំនឹងមិនស៊ើបអង្កេតថែមទៀតលើអង្គហេតុពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មទី ៨, ១៤, ១៥, ២៣, ២៤ និង ២៥។

១០. **ជូនដំណឹង** ភាគីទាំងអស់ថា ខ្ញុំមិនមានបំណងអនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន* ចំពោះអង្គហេតុពាក់ព័ន្ធនឹងបទចោទស្តីពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ទេ។

១១. **ជូនដំណឹង** ភាគីទាំងអស់ថា សេចក្តីសម្រេចលើការអនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន* នឹងត្រូវធ្វើឡើងនៅពេលបញ្ចប់កិច្ចស៊ើបសួរ។

ភ្នំពេញ ថ្ងៃទី១៧ ខែ មីនា ឆ្នាំ ២០១៧

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**